# ប្រកាសចូលកាន់មុខតំណែងប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តបាត់ដំបងថ្មី




**(បាត់ដំបង)៖** លោក តូច ឈួនសៅរិទ្ធ ត្រូវបានប្រកាសឲ្យចូលកាន់មុខតំណែងជាប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តបាត់ដំបងថ្មី ជំនួសលោក សំបូរ ផូ ដែលត្រូវបានចូលនិវត្តន៍ ក្រោមអធិបតីភាពឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងលោក ងួន រតនៈ អភិបាល នៃគណៈអភិបាលខេត្តបាត់ដំបង។



ពិធីខាងលើបានធ្វើឡើងនាព្រឹកថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៨នេះ នៅសាលប្រជាសាលាខេត្ត ដោយមានការអញ្ជើញចូលរួមពីក្រុមប្រឹក្សាខេត្ត អភិបាលក្រុងស្រុក ថ្នាក់ដឹកនាំ មន្ត្រីរាជការ កងកម្លាំង មន្ទីរស្ថាប័នរដ្ឋនានានៅជុំវិញខេត្ត មន្ត្រីមន្ទីរឧស្សាហកម្មនិងសិប្បកម្មជាច្រើនរូបទៀត។



លោក តូច ឈួនសៅរិទ្ធ ដែលទើបទទួលការតែងតាំងថ្មី បានឡើងមានចំណាប់អារម្មណ៍ និងប្តេជ្ញាចិត្តដឹកនាំស្ថានប័ននេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ មានសាមគ្គីភាពផ្ទៃក្នុងល្អ សហការជាមួយជំនាញនានា និងអាជ្ញាធរខេត្ត ដើម្បីចូលរួមបម្រើសេវាឱ្យបានលឿនរហ័ស ជូនប្រជាពលរដ្ឋផងដែរ។



ក្នុងឱកាសនោះដែរ ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ និងឯកឧត្តម ងួន រតនៈ បានសង្កត់ធ្ងន់ថា ក្នុងនាមក្រសួងជំនាញ ត្រូវបានពង្រឹងការងារនានា ក្នុងវិស័យឧស្សាហកម្ម និងសិប្បកម្មលើវិស័យឯកជន នៅតាមបណ្តាសិប្បកម្ម សហគ្រាសខ្នាតតូចនិងមធ្យម ក្នុងខេត្តបាត់ដំបង ដែលបានផលិតទំនិញគ្រប់ប្រភេទ សូមឱ្យមានការវេចខ្ចប់មានអនាម័យខ្ពស់ តាមស្តង់ដា ដែលអាចទទួលយកបានជានាគុណភាព មិនធ្វើឱ្យប៉ះពាល់សុខភាព អ្នកប្រើប្រាស់ឡើយ។



ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត បានបន្តថា ដោយឡែកបណ្តាញទឹកស្អាតវិញ បាននឹងកំពុងអនុវត្ត ជាបន្តបន្ទាប់ធ្វើឱ្យបានដល់ផ្ទះប្រជាពលរដ្ឋនៅតាមជនបទនាពេលខាងមុខនេះ។ នៅក្នុងអណត្តិទី៦នេះ រាជរដ្ឋាភិបាលថ្មីបានដាក់ទិសដៅកែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យ ដើម្បីគាំពារ និងផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋយើង នៅគ្រប់ទិសទីទាំងនៅទីក្រុង និងជនបទ ដើម្បីកាត់បន្ថយការលំបាកចាកចេញពីភាពក្រីក្រ របស់ប្រជាពលរដ្ឋឲ្យមានជីវភាពកាន់តែប្រសើ ឡើងតទៅ។